# ៤. មធ្យោបាយពន្យារកំណើតអចិន្ត្រៃយ៍







+ ការចោះចងដៃស្បូន
  - គឺការចោះរន្ធតូចមួយនៅលើពោះ ដើម្បីរកដៃស្បូនទាំងពីរ ចងនិងកាត់ផ្តាច់ម្តងមួយៗ។ ការចោះនេះត្រូវប្រើថ្នាំស្ពឹកត្រង់កន្លែងចោះ។ សមស្របចំពោះស្ត្រីដែលមិនចង់បានកូនទៀត ឬ មានបញ្ហាផ្នែកវេជ្ជសាស្ត្រ។

+ ការចោះចងបំពង់បង្ហូរមេជីវិតឈ្មោល
  - គឺជាការចោះរន្ធតូចមួយនៅលើស្បែកពងស្វាស ដើម្បីរកបំពង់បង្ហូរមេជីវិតឈ្មោលទាំងពីរ រួចចង និងកាត់ផ្តាច់វាម្តងមួយៗ ការចោះនេះត្រូវប្រើថ្នាំស្ពឹក។ សមស្របចំពោះបុរសដែលមិនចង់បានកូនទៀត ឬមួយក៏ដៃគូរបស់គាត់មានបញ្ហាផ្នែកវេជ្ជសាស្ត្រ។



**មុននឹងប្រើសូមទៅពិគ្រោះជាមួយ**
**អ្នកផ្តល់សេវានៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ**

## ឯកសារយោង


- ពិធីសារជាតិស្តីអំពីការពន្យារកំណើត ឆ្នាំ២០១៦ ជាភាសារខ្មែរ / ក្រសួងសុខាភិបាល / កម្មវិធីជាតិសុខភាពបន្តពូជ
- សៀវភៅបិទបើកស្តីអំពីការពន្យារកំណើត ឆ្នាំ២០១០ ជាភាសាខ្មែរ / ក្រសួងសុខាភិបាល / កម្មវិធីជាតិសុខភាពបន្តពូជ


ក្រសួងសុខាភិបាល Ministry of Health | SCGO: Cambodian Society of Gynecology and Obstetrics | JSOG: Japan Society of Obstetrics and Gynecology | NCGM: National Center for Global Health and Medicine | JICA: Japan International Cooperation Agency

ព័ត៌មានរបស់សមាគមសម្ភព
និងរោគស្ត្រីវិទ្យាកម្ពុជា
គេហទំព័រ: www.scgo-kh.com


ផលិតដោយ SCGO
ឧបត្ថម្ភដោយ JSOG, NCGM, and JICA

បោះពុម្ពលើកទី១ ឆ្នាំ២០១៨


© រក្សាសិទ្ធិគ្រប់យ៉ាង


មានកូនតាមប្រាថ្នា ប្រសើរជាងមានកូនដោយចៃដន្យ

# ការពន្យារកំណើត



## សារៈប្រយោជន៍នៃការពន្យារកំណើត

- ម្តាយ និងកូនមានសុខភាពល្អ
- ឪពុក ម្តាយមានពេលវេលាគ្រប់គ្រាន់ សម្រាប់ថែទាំកូនឱ្យបានល្អ
- កូនអាចបៅដោះម្តាយបានយូរ
- គ្រួសារមានពេលប្រកបមុខរបរ និងមានជីវភាពធូរធារ
- កាត់បន្ថយគ្រោះថ្នាក់ក្នុងពេលស្ត្រីមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាល
- គ្រួសារដែលមានកូនរង្វើល មានសុខភាពល្អ មានជីវភាពធូរធារ និងមិនសូវមានបញ្ហា
- បន្ថយគ្រោះថ្នាក់ពីការមានផ្ទៃពោះដែលមិនចង់បាន និងជៀសវាងការរំលូតកូនដែលមិនមានសុវត្ថិភាព។

# ការពន្យារកំណើត

គឺជាការជ្រើសរើសចំនួនកូនក្នុងគ្រួសារ និងការពន្យារពេលពីកំណើតកូនមួយ ទៅកំណើតកូនមួយទៀត រយៈពេល៣ឆ្នាំយ៉ាងតិច។
មធ្យោបាយពន្យារកំណើតមានច្រើនប្រភេទគឺ ៖

## ១. មធ្យោបាយរបាំង :

### ស្រោមអនាម័យសំរាប់បុរស



- ជាបំពង់កៅស៊ូស្តើងមានចុងម្ខាងបិទជិត ដែលប្រើដោយបុរសនៅពេលរួមភេទ។
- ស្រោមអនាម័យមួយអាចប្រើបានតែម្តងគត់
- ប្រើស្រោមអនាម័យមិនធ្វើឱ្យស្ត្រីរលាកស្បូនទេ
- មានប្រសិទ្ធិភាពនៅពេលដែលពាក់ស្រោមអនាម័យបានត្រឹមត្រូវ
- ការពារការមានផ្ទៃពោះ ជំងឺកាមរោគ និងជំងឺអេដស៍

## ២. មធ្យោបាយដែលមានជាតិអ័រម៉ូន :

### ថ្នាំគ្រាប់



+ ថ្នាំ១បន្ទះមាន២៨គ្រាប់ អាចការពារមិនឱ្យមានផ្ទៃពោះបាន១ខែ។
  - ត្រូវលេបថ្នាំ១ថ្ងៃ១គ្រាប់តាមសញ្ញាព្រួញរៀងរាល់ថ្ងៃក្នុងម៉ោងដដែល
  - ស្ត្រីនឹងមានកូនវិញក្រោយពីឈប់លេបថ្នាំ
  - ធ្វើឱ្យឈាមរដូវទៀងទាត់ ២៨ថ្ងៃ
  - អាចកាត់បន្ថយភាពស្លេកស្លាំង ដុំកន្សោមពង ជំងឺមហារីកកន្សោមពង ស្រទាប់ក្នុងនៃស្បូន និងរលាកអាងត្រគាក

### ថ្នាំគ្រាប់ការពារកំណើតបន្ទាន់



ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ គឺជាថ្នាំគ្រាប់ដែលគេប្រើភ្លាមៗ ក្នុងអំឡុងពេល ៧២ម៉ោង បន្ទាប់ពីមានការរួមភេទដែលមិនបានការពារ។ មានប្រសិទ្ធិភាពខ្ពស់ប្រសិនបើឆាប់ប្រើក្រោយការរួមភេទដែលមិនបានការពារ ឬត្រូវបានគេចាប់រំលោភ។



**ប៉ុន្តែ មិនអាចប្រើជាមធ្យោបាយពន្យារកំណើតជាប្រចាំបានទេ មិនអាចការពារការឆ្លងរោគតាមផ្លូវបន្តពូជ និងមិនអាចប្រើជាមធ្យោបាយរំលូតកូនទេ។**

### ថ្នាំចាក់



+ ថ្នាំចាក់ គឺជាថ្នាំមានជាតិអ័រម៉ូនប្រូសេស្តូសែន តែមួយមុខ ១៥០ម.ក្រ។ ថ្នាំពន្យារកំណើត ១ម្ជុល
  - អាចការពារមិនឱ្យមានផ្ទៃពោះបាន៣ខែ
  - មានប្រសិទ្ធិភាពខ្ពស់ប្រសិនបើប្រើបានត្រឹមត្រូវ
  - មិនរំខានដល់ការរួមភេទ
  - ស្ត្រីអាចបាត់ឈាមរដូវមួយរយៈ ក្រោយពីចាក់ថ្នាំ តែមិនប៉ះពាល់ដល់សុខភាពទេ
  - អាចកាត់បន្ថយភាពស្លេកស្លាំង
  - ជួយការពារស្ត្រីកុំឱ្យមានជំងឺមហារីកមួយចំនួន (កន្សោមពង ស្រទាប់ក្នុងនៃស្បូន)
  - អាចការពារស្ត្រីមិនឱ្យមានជំងឺរលាកអាងត្រគាក

## ៣. មធ្យោបាយពន្យារកំណើតមានរយៈពេលយូរ

### កងដាក់ក្រោមស្បែក



កងដាក់ក្រោមស្បែកគឺជាបំពង់ស៊ីលីកូនដែលមានផ្ទុកជាតិអ័រម៉ូន ត្រូវបានដាក់បញ្ចូលក្រោមស្បែកផ្នែកខាងក្នុងនៃដើមដៃ។

កងដាក់ក្រោមស្បែកមានច្រើនប្រភេទ ដូចជា ៖
ចាឌែល (Jadelle) ជាបំពង់តូចឆ្មារ មានចំនួន២ដើម អាចការពារមិនឱ្យមានកូនរយៈពេល៥ឆ្នាំ។ ចំណែកឯអ៊ីមផ្លាណុន (Implanon) ជាបំពង់តូចឆ្មារ ទន់ អាចបត់បែនបាន មានចំនួន១ដើម អាចការពារមិនឱ្យមានកូនរយៈពេល៣ឆ្នាំ។
ស្ត្រីអាចធ្វើការងារដូចធម្មតា ស្ត្រីអាចមានរដូវមិនទៀងទាត់ ឬអាចបាត់ឈាមរដូវមួយរយៈ។

### កងដាក់ក្នុងស្បូន (TCu 380A)



កងTCu 380A មានរាងដូចអក្សរតេ "T" ជាវត្ថុប្លាស្ទិកតូច អាចបត់បែនបាន។ នៅដៃសងខាងនៃអក្សរតេ "T" និងនៅលើតួ មានរុំខ្សែទង់ដែង មានប្រសិទ្ធភាពខ្ពស់ អាចការពារការមានផ្ទៃពោះបានរហូតដល់ ១០ឆ្នាំ។

- មិនរំខានដល់ការងារប្រចាំថ្ងៃរបស់ស្ត្រី
- មិនរំខានដល់ការរួមភេទ
- អាចការពារជំងឺមហារីកស្រទាប់ក្នុងនៃស្បូន
- អាចមានឈាមរដូវច្រើនជាងមុន (បរិមាណច្រើន និងរយៈពេលវែង)